អេស៊ីលីដា
ACLEDA BANK

# សេចក្ដីជូនដំណឹង

## ស្ដីពី

## កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញលើកទី២៤ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

**ធនាគារ អេស៊ីលីដា ភីអិលស៊ី** (“ធនាគារ អេស៊ីលីដា”) មានកិត្តិយស សូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកទាំងអស់ ជ្រាបថា ដោយអនុលោមតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល **ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤** ធនាគារ អេស៊ីលីដា នឹងរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញ (“កិច្ចប្រជុំ”) តាមរយៈប្រព័ន្ធ **Video Con-Call** នៅ**ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤** វេលាម៉ោង**១៤:០០ រសៀល**។

**របៀបវារៈនៃកិច្ចប្រជុំនេះ ត្រូវបានកំណត់ដូចខាងក្រោម៖**

| ល.រ | របៀបវារៈ | ម៉ោង |
|---|---|---|
| **១. បើកកិច្ចប្រជុំ** | | |
| ១.១. | មតិស្វាគមន៍របស់ប្រធានមហាសន្និបាត | ១៤:០០ - ១៤:០៥ |
| ១.២. | ការណែនាំសមាជិក-សមាជិកាក្រុមប្រឹក្សាភិបាល | ១៤:០៥ - ១៤:១០ |
| ១.៣. | អនុម័តរបៀបវារៈនៃកិច្ចប្រជុំ និងបទបង្ហាញអំពីដំណើរការនៃការបោះឆ្នោត | ១៤:១០ - ១៤:១៥ |
| **២. សេចក្ដីសម្រេច** | | |
| ២.១. | អនុម័តការបែងចែកភាគលាភ សម្រាប់ប្រាក់ចំណេញក្នុងឆ្នាំ២០២៣ និងរក្សាប្រាក់ចំណេញដែលនៅសល់ក្នុងខ្ទង់ប្រាក់ចំណេញរក្សាទុក ដែលនឹងត្រូវអនុម័តចុងក្រោយដោយអាជ្ញាធរពាក់ព័ន្ធ | ១៤:១៥ - ១៤:២៥ |
| ២.២. | អនុម័តការបង្កើនដើមទុន តាមរយៈការបែងចែកភាគលាភជាភាគហ៊ុន | ១៤:២៥ - ១៤:៣៥ |
| ២.៣. | អនុម័តការធ្វើវិសោធនកម្មលើមាត្រា៦ មាត្រា៨ ឧបសម្ព័ន្ធ៣ និងឧបសម្ព័ន្ធ៤ នៃលក្ខន្តិកៈ ធនាគារ អេស៊ីលីដា | ១៤:៣៥ - ១៤:៤៥ |
| ២.៤. | អនុម័តកម្រៃសេវាសម្រាប់ក្រុមប្រឹក្សាភិបាល ២.១% ស្របតាមអត្រាអតិផរណាឆ្នាំ២០២៣ | ១៤:៤៥ - ១៤:៥៥ |
| ២.៥. | អនុម័តការដំឡើងប្រាក់បៀវត្សប្រចាំឆ្នាំសម្រាប់ប្រធានក្រុមប្រឹក្សាភិបាល | ១៤:៥៥ - ១៥:០៥ |
| ២.៦. | អនុម័តលើការតែងតាំង **លោក Constant Tilman** ជាតំណាងភាគហ៊ុនិកថ្មី មកពី TMF and TFSF (Triodos) នៅធនាគារ អេស៊ីលីដា ជំនួសលោកស្រី Farah Katia Chams | ១៥:០៥ - ១៥:១៥ |
| ២.៧. | អនុម័តលើការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាល សម្រាប់បន្តអាណត្តិថ្មី | ១៥:១៥ - ១៥:២៥ |
| ២.៨. | អនុម័តកាលបរិច្ឆេទកំណត់ទុកសម្រាប់ភាគហ៊ុនិក ដែលត្រូវទទួលបានភាគលាភ | ១៥:២៥ - ១៥:៣៥ |
| **៣. បញ្ហាដែលត្រូវពិភាក្សា និងរបាយការណ៍/បទបង្ហាញ** | | |
| ៣.១. | បទបង្ហាញ ស្ដីពីរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ របស់ធនាគារ អេស៊ីលីដា ដែលបានធ្វើសវនកម្មរួច សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | ១៥:៣៥ - ១៥:៤៥ |
| ៣.២. | របាយការណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល សម្រាប់ឆ្នាំ២០២៣ | ១៥:៤៥ - ១៥:៥៥ |
| ៣.៣. | របាយការណ៍របស់ប្រធាននាយកប្រតិបត្តិ សម្រាប់ឆ្នាំ២០២៣ | ១៥:៥៥ - ១៦:០៥ |
| **៤. បញ្ហាដែលត្រូវកំណត់ចំណាំ** | | |
| ៤.១. | ផ្សេងៗ | ១៦:០៥ - ១៦:១០ |

ចុះបញ្ជីក្រោមលេខ
Registration No. 00003077

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Building Nº 61, Preah Monivong Blvd., Sangkat Srah Chak, Khan Doun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP

| | | |
|---|---|---|
| ៤.២. | ប្រកាសលទ្ធផលនៃការបោះឆ្នោត | ១៦:១០ - ១៦:២៥ |
| **៥. មតិបិទកម្មវិធី** | | ១៦:២៥ - ១៦:៣០ |

## ដំណើរការនៃកិច្ចប្រជុំ

### មុនពេលកិច្ចប្រជុំ

| ឯកសារ | ជំហាន-១ | ជំហាន-២ | ជំហាន-៣ | កាលបរិច្ឆេទផ្ញើ (ម៉ោងនៅភ្នំពេញ) | |
|---|---|---|---|---|---|
| | | | | ចាប់ពី | ដល់ |
| ១. លិខិតអញ្ជើញ | ✓ | | | ២៨-មីនា-២០២៤ | ៣-មេសា-២០២៤ |
| ២. លិខិតប្រគល់សិទ្ធិ | ✓ | | | | |
| ៣. ការបញ្ជាក់ពីការចូលរួមក្នុងកិច្ចប្រជុំតាមរយៈភ្នាក់ងារ RTP | ✓ | | | | |
| ៤. តំណភ្ជាប់សម្រាប់ការចុះឈ្មោះដើម្បីចូលរួមកិច្ចប្រជុំ | | ✓ | | ៣-មេសា-២០២៤ | ១២-មេសា-២០២៤ |
| ៥. ឯកសារគាំទ្រ | | ✓ | | | |
| ៦. សេចក្ដីណែនាំអំពីការបោះឆ្នោត | | ✓ | | | |
| ៧. តំណភ្ជាប់សម្រាប់ការចូលរួមកិច្ចប្រជុំ | | | ✓ | ២២-មេសា-២០២៤ | ២៤-មេសា-២០២៤ |
| ៨. ឃ្យូអរកូដសម្រាប់ការបោះឆ្នោត | | | ✓ | | |

**ជំហាន-១៖** ភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីភាគហ៊ុនិកនៅកាលបរិច្ឆេទកំណត់ទុក**ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៤** នឹងទទួលបានឯកសារក្នុងបញ្ជី**លេខ១** ដល់**លេខ២** តាមរយៈអ៊ីម៉ែល។ ករណីដែលភាគហ៊ុនិករូបណាពុំអាចចូលរួម និងបោះឆ្នោតតាមកាលបរិច្ឆេទ និងពេលវេលាកំណត់ ភាគហ៊ុនិករូបនោះអាចចាត់បុគ្គលណាម្នាក់ធ្វើជាតំណាងខ្លួន ដើម្បីចូលរួម និងបោះឆ្នោត។ ភាគហ៊ុនិកត្រូវបញ្ជាក់ពីការចូលរួមក្នុងកិច្ចប្រជុំរបស់ខ្លួនដោយផ្ទាល់ ឬអ្នកទទួលសិទ្ធិរបស់ខ្លួន និងត្រូវផ្ញើនូវ**លិខិតប្រគល់សិទ្ធិ** ទៅ**ភ្នាក់ងារ RTP** តាមរយៈមធ្យោបាយអេឡិចត្រូនិក ចាប់ពី **ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៤** ដល់**ថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៤** យ៉ាងយូរបំផុតនៅត្រឹម**ម៉ោង១២:០០ ថ្ងៃត្រង់**។

**ជំហាន-២៖** **ភ្នាក់ងារ RTP** នឹងផ្ញើឯកសារ ដែលមានក្នុងបញ្ជី**លេខ៤** ដល់**លេខ៦** តាមរយៈអ៊ីម៉ែល ជូនដល់ភាគហ៊ុនិក ដែលបានបញ្ជាក់ពីការចូលរួមក្នុងកិច្ចប្រជុំតែប៉ុណ្ណោះ។ ភាគហ៊ុនិកត្រូវចុះឈ្មោះ សម្រាប់ការចូលរួមកិច្ចប្រជុំចាប់ពី**ថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៤** ដល់**ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៤**។

**ជំហាន-៣៖** ចាប់ពី**ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៤** ដល់**ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៤** **ភ្នាក់ងារ RTP** នឹងផ្ញើឯកសារក្នុងបញ្ជី**លេខ៧** ដល់**លេខ៨** តាមរយៈអ៊ីម៉ែល ជូនដល់ភាគហ៊ុនិក និងអ្នកទទួលសិទ្ធិ ដែលបានបំពេញតំណភ្ជាប់សម្រាប់ការចុះឈ្មោះដើម្បីចូលរួមកិច្ចប្រជុំតែប៉ុណ្ណោះ។

**កំលុងពេលកិច្ចប្រជុំ៖**

- ភាគហ៊ុនិក និងអ្នកទទួលសិទ្ធិម្នាក់ៗ អាចចូលរួមកិច្ចប្រជុំយ៉ាងហោច **១៥នាទីមុនពេលកិច្ចប្រជុំចាប់ផ្ដើម** តាមរយៈតំណភ្ជាប់ដែលនឹងត្រូវផ្ញើជូនដោយ **ភ្នាក់ងារ RTP** របស់ធនាគារ អេស៊ីលីដា។
- ភាគហ៊ុនិក និងអ្នកទទួលសិទ្ធិម្នាក់ៗ ត្រូវបោះឆ្នោតតាមរបៀបវារៈនីមួយៗ នៃកិច្ចប្រជុំ បន្ទាប់ពីការប្រកាសរបស់ប្រធានអង្គប្រជុំ តាមរបៀបវារៈនីមួយៗ។

***សម្គាល់៖** ធនាគារ អេស៊ីលីដា សូមរក្សាសិទ្ធិផ្លាស់ប្ដូររបៀបនៃកិច្ចប្រជុំ តាមករណីចាំបាច់ ដោយធ្វើការជូនដំណឹងជាមុន។*

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកផ្នែកប្រតិបត្តិការបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ (**ភ្នាក់ងារ RTP**) ដូចខាងក្រោម៖

- **លោក ហួត សុភី** ប្រធានផ្នែកប្រតិបត្តិការ RTP
  - ទូរស័ព្ទ: (៨៥៥) ១៥ ៩០០ ៥៣៨
  - អ៊ីម៉ែល: huot.sophy@acledabank.com.kh

- **លោក កែន រិទ្ធពុទ្ធា** អ្នកឯកទេសបឋមប្រតិបត្តិការ RTP
    - ទូរស័ព្ទ: (៨៥៥) ១៥ ៨០០ ៦៦៣
    - អ៊ីម៉ែល: ken.rithputhea@acledabank.com.kh
- **លោកស្រី សំរិទ្ធ វណ្ណីបុប្ផារដ្ឋ** អ្នកឯកទេសបឋមប្រតិបត្តិការ RTP
    - ទូរស័ព្ទ: (៨៥៥) ៦១ ២៨៧ ៧៦៦
    - អ៊ីម៉ែល: op.rtp@acledabank.com.kh

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមភាគហ៊ុនិកទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**